**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ០១ សណន

# សេចក្តីណែនាំ
# ស្តីពី
# ការតែងតាំងឡើងវិញមន្ត្រីរាជការស៊ីវិល និងការរៀបចំមន្ត្រីទៅក្នុងរចនាសម្ព័ន្ធថ្មី របស់ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួង រដ្ឋលេខាធិការដ្ឋាន និងស្ថាប័នចំណុះអង្គការនីតិប្រតិបត្តិ

ក្នុងក្របខ័ណ្ឌនៃការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា រាជរដ្ឋាភិបាលបានដាក់ចេញនូវសារាចរលេខ០៨ សរ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៤ ស្តីពីការរៀបចំនិងការកែសម្រួលរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន សារាចរលេខ០៥ សរ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៥ ស្តីពីការកំណត់ និងការអនុវត្តមុខងារនៅតាមក្រសួង ស្ថាប័ន ចំណុះអង្គការនីតិប្រតិបត្តិ និងសេចក្តីណែនាំលេខ០១ សណន ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៤ ស្តីពីការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធក្រសួង ស្ថាប័ន ដើម្បីពង្រឹងសមត្ថភាពរបស់ក្រសួង ស្ថាប័នក្នុងការអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួនឱ្យកាន់តែមានប្រសិទ្ធភាព ឆ្លើយតបទៅនឹងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា។

ដើម្បីធានាដល់ការតែងតាំងឡើងវិញមន្ត្រីរាជការស៊ីវិល និងការរៀបចំមន្ត្រីទៅក្នុងរចនាសម្ព័ន្ធថ្មី របស់ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួង រដ្ឋលេខាធិការដ្ឋាន និងស្ថាប័នចំណុះអង្គការនីតិប្រតិបត្តិ ស្របតាមអភិក្រម "រៀបចំផ្ទះឱ្យរៀបរយ" និង "ពង្រឹងជាជាងពង្រីក" ព្រមទាំងរក្សានូវអត្ថប្រយោជន៍ជូនមន្ត្រីរាជការស៊ីវិល រាជរដ្ឋាភិបាល សូមធ្វើការណែនាំដូចខាងក្រោម៖

## ១- ការរៀបចំតែងតាំងឡើងវិញមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងគ្រប់គ្រងនិងថ្នាក់ប្រហាក់ប្រហែលទៅតាមរចនាសម្ព័ន្ធថ្មី

### ១.១- គោលការណ៍រួម

១.១.១- ការរៀបចំតែងតាំងឡើងវិញមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងគ្រប់គ្រងនិងថ្នាក់ប្រហាក់ប្រហែលទៅតាមរចនាសម្ព័ន្ធថ្មី ត្រូវតែងតាំងតែមន្ត្រីរាជការស៊ីវិលទាំងឡាយណាដែលបាននិងកំពុងកាន់មុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនិងថ្នាក់ប្រហាក់ប្រហែលដែលមានស្រាប់ លើកលែងរចនាសម្ព័ន្ធថ្មីត្រូវការចាំបាច់នូវមន្ត្រីរាជការស៊ីវិលដែលមានគុណសម្បត្តិស័ក្តិសម ស្របតាមតម្រូវការរបស់អង្គភាពថ្មី។



ម៩

១.១.២- ការរៀបចំតែងតាំងឡើងវិញមន្ត្រីរាជការស៊ីវិល ថ្នាក់អគ្គលេខាធិការរង ឬអគ្គនាយករង ឬអគ្គាធិការរង ឬអនុប្រធាននាយកដ្ឋាន ឬអធិការរង ឬអនុប្រធានការិយាល័យ ឬថ្នាក់ប្រហាក់ប្រហែលទៅតាមរចនាសម្ព័ន្ធថ្មី ត្រូវអនុវត្តត្រឹមចំនួនដែលមានស្រាប់ប៉ុណ្ណោះ លើកលែងក្នុងករណីដែលមានចែងក្នុងចំណុច ១.២.១ និងចំណុច ១.៣.១ នៃសេចក្តីណែនាំនេះ។

១.១.៣- មន្ត្រីរាជការស៊ីវិលដែលត្រូវបានប៉ះពាល់ដោយការរៀបចំនិងការកែសម្រួលរចនាសម្ព័ន្ធថ្មី ត្រូវរក្សាទុកអត្ថប្រយោជន៍ផ្នែកបៀវត្សយ៉ាងហោចក្នុងកម្រិតដដែល។

១.១.៤- ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួង រដ្ឋលេខាធិការដ្ឋាន និងស្ថាប័នចំណុះអង្គការនីតិប្រតិបត្តិ ត្រូវរៀបចំតែងតាំងមន្ត្រីរាជការស៊ីវិលទៅតាមរចនាសម្ព័ន្ធថ្មីឱ្យបានរួចរាល់ យ៉ាងយូរបំផុតត្រឹមរយៈពេល ៣(បី)ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការអនុវត្តលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការរៀបចំនិងការកែសម្រួលរចនាសម្ព័ន្ធថ្មី ឬយ៉ាងយូរបំផុតត្រឹមរយៈពេល ៣(បី)ខែ បន្ទាប់ពីសេចក្តីណែនាំនេះចូលជាធរមាន។

**១.២- ការរៀបចំតែងតាំងឡើងវិញមន្ត្រីរាជការស៊ីវិលទៅក្នុងមុខតំណែងគ្រប់គ្រងថ្នាក់អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ អគ្គលេខាធិការរង អគ្គនាយករង អគ្គាធិការរង ឬថ្នាក់ប្រហាក់ប្រហែល**

១.២.១- ក្នុងករណីដែលមានការរៀបចំកែសម្រួលរចនាសម្ព័ន្ធដោយលុប ឬបញ្ចូលអង្គភាពថ្នាក់អគ្គនាយកដ្ឋាន ឬថ្នាក់ប្រហាក់ប្រហែលពីរឬច្រើនទៅជាអង្គភាពតែមួយ ត្រូវរៀបចំកែសម្រួលភារកិច្ចរបស់អគ្គលេខាធិការ ឬអគ្គនាយក ឬអគ្គាធិការ ឬថ្នាក់ប្រហាក់ប្រហែល ដែលមិនទទួលបានការតែងតាំងឡើងវិញជាអគ្គលេខាធិការ ឬអគ្គនាយក ឬអគ្គាធិការ ឬថ្នាក់ប្រហាក់ប្រហែល ទៅជាអគ្គលេខាធិការរង ឬអគ្គនាយករង ឬអគ្គាធិការរង ឬថ្នាក់ប្រហាក់ប្រហែល ដោយរក្សាប្រាក់បំណាច់មុខងារជាអគ្គលេខាធិការ ឬអគ្គនាយក ឬអគ្គាធិការ ឬថ្នាក់ប្រហាក់ប្រហែល និងអត្ថប្រយោជន៍ផ្សេងទៀតនៅកម្រិតដដែល។

១.២.២- រៀបចំតែងតាំងឡើងវិញមន្ត្រីរាជការស៊ីវិល ដែលបាននិងកំពុងកាន់មុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងថ្នាក់អគ្គលេខាធិការរង ឬអគ្គនាយករង ឬអគ្គាធិការរង ឬថ្នាក់ប្រហាក់ប្រហែល ទៅតាមរចនាសម្ព័ន្ធថ្មី។

**១.៣-ការរៀបចំតែងតាំងឡើងវិញមន្ត្រីរាជការស៊ីវិលទៅក្នុងមុខតំណែងគ្រប់គ្រងថ្នាក់នាយកដ្ឋាន អនុប្រធាននាយកដ្ឋាន ឬថ្នាក់ប្រហាក់ប្រហែល**

១.៣.១-ក្នុងករណីដែលមានការរៀបចំកែសម្រួលរចនាសម្ព័ន្ធដោយលុប ឬបញ្ចូលអង្គភាពថ្នាក់នាយកដ្ឋាន ឬថ្នាក់ប្រហាក់ប្រហែលពីរឬច្រើនទៅជាអង្គភាពតែមួយ មន្ត្រីរាជការស៊ីវិលដែលមិនត្រូវបានទទួលការតែងតាំងជាប្រធាននាយកដ្ឋានឡើងវិញ នឹងត្រូវពិនិត្យនិងរៀបចំការតែងតាំងផ្អែកលើជម្រើសដូចខាងក្រោម៖

- លើកសំណើសុំតែងតាំងទៅក្នុងមុខតំណែងគ្រប់គ្រងថ្នាក់អគ្គលេខាធិការរង ឬអគ្គនាយករង ឬអគ្គាធិការរង ឬថ្នាក់ប្រហាក់ប្រហែល ដោយផ្អែកលើទំហំការងារ និងលក្ខណសម្បត្តិស័ក្តិសម ឬ

- លើកសំណើសុំកែសម្រួលភារកិច្ចទៅក្នុងមុខតំណែងគ្រប់គ្រងថ្នាក់អនុប្រធាននាយកដ្ឋាន ឬអធិការរង ឬថ្នាក់ប្រហាក់ប្រហែល ដោយត្រូវរក្សាប្រាក់បំណាច់មុខងារជាប្រធាននាយកដ្ឋាន ឬអធិការ ឬថ្នាក់ប្រហាក់ប្រហែល និងអត្ថប្រយោជន៍ផ្សេងទៀតនៅកម្រិតដដែល។

១.៣.២- រៀបចំតែងតាំងឡើងវិញមន្ត្រីរាជការស៊ីវិល ដែលបាននិងកំពុងកាន់មុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងថ្នាក់អនុប្រធាននាយកដ្ឋាន ឬថ្នាក់ប្រហាក់ប្រហែល ទៅតាមរចនាសម្ព័ន្ធថ្មី។

**១.៤- ការរៀបចំតែងតាំងឡើងវិញមន្ត្រីរាជការស៊ីវិលទៅក្នុងមុខតំណែងគ្រប់គ្រងថ្នាក់ការិយាល័យ អនុប្រធានការិយាល័យ ឬថ្នាក់ប្រហាក់ប្រហែល**

១.៤.១- ក្នុងករណីដែលមានការរៀបចំកែសម្រួលរចនាសម្ព័ន្ធដោយលុប ឬបញ្ចូលអង្គភាពថ្នាក់ការិយាល័យ ឬថ្នាក់ប្រហាក់ប្រហែលពីរឬច្រើនទៅជាអង្គភាពតែមួយ មន្ត្រីរាជការស៊ីវិលដែលមិនត្រូវបានទទួលការតែងតាំងជាប្រធានការិយាល័យ ឬថ្នាក់ប្រហាក់ប្រហែលឡើងវិញ នឹងត្រូវពិនិត្យនិងរៀបចំកែសម្រួលភារកិច្ចទៅក្នុងមុខតំណែងគ្រប់គ្រងថ្នាក់អនុប្រធានការិយាល័យ ឬថ្នាក់ប្រហាក់ប្រហែល ដោយត្រូវរក្សាប្រាក់បំណាច់មុខងារជាប្រធានការិយាល័យ ឬថ្នាក់ប្រហាក់ប្រហែល និងអត្ថប្រយោជន៍ផ្សេងទៀតនៅកម្រិតដដែល។

១.៤.២- រៀបចំតែងតាំងឡើងវិញមន្ត្រីរាជការស៊ីវិល ដែលបាននិងកំពុងកាន់មុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងថ្នាក់អនុប្រធានការិយាល័យ ឬថ្នាក់ប្រហាក់ប្រហែល ទៅតាមរចនាសម្ព័ន្ធថ្មី។

## ២- ការរៀបចំតែងតាំងមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងគ្រប់គ្រងនិងថ្នាក់ប្រហាក់ប្រហែលទៅតាមរចនាសម្ព័ន្ធថ្មី

២.១- បន្ទាប់ពីការរៀបចំតែងតាំងឡើងវិញមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងគ្រប់គ្រងនិងថ្នាក់ប្រហាក់ប្រហែលគ្រប់កម្រិត ទៅក្នុងរចនាសម្ព័ន្ធថ្មីចប់សព្វគ្រប់ ប្រសិនមានភាពចាំបាច់សម្រាប់ការដឹកនាំនិងគ្រប់គ្រងអង្គភាពឱ្យមានប្រសិទ្ធភាព ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួង រដ្ឋលេខាធិការដ្ឋាន និងស្ថាប័នចំណុះអង្គការនីតិប្រតិបត្តិ អាចលើកសំណើសុំកែសម្រួលភារកិច្ចឬតែងតាំងមន្ត្រីរាជការស៊ីវិលក្នុងរចនាសម្ព័ន្ធថ្មីបាន ដោយត្រូវអនុវត្តទៅតាមបែបបទ នីតិវិធី និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

២.២- ការរៀបចំតែងតាំងមន្ត្រីរាជការស៊ីវិលផ្សេងក្នុងមុខតំណែងគ្រប់គ្រងនិងថ្នាក់ប្រហាក់ប្រហែលគ្រប់កម្រិតនៃរចនាសម្ព័ន្ធថ្មី អាចអនុវត្តបានក្នុងករណីដែលមានមុខតំណែងទំនេរ ដោយហេតុលាឈប់ មរណភាព បោះបង់ការងារ បាត់បង់សម្បទាវិជ្ជាជីវៈ ឬកំពុងជាប់ការចោទប្រកាន់ទៅតុលាការជំនុំជម្រះ ឬទទួលការផ្តន្ទាទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋ ផ្អែកលើទំហំការងារ គុណសម្បត្តិស័ក្តិសម និងត្រូវអនុវត្តស្របតាមបែបបទ នីតិវិធី និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ៣- នីតិវិធីអនុវត្តនិងការតាមដានត្រួតពិនិត្យ

៣.១- ប្រគល់ភារកិច្ចជូនគណៈកម្មាធិការលើកកម្ពស់អភិបាលកិច្ចរបស់ក្រសួង ស្ថាប័ន ក្នុងការតាមដានត្រួតពិនិត្យនិងជំរុញការអនុវត្តឱ្យស្របតាមខ្លឹមសារនៃសេចក្តីណែនាំនេះ និងរៀបចំសំណើសុំតែងតាំងឡើងវិញមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងគ្រប់គ្រងនិងថ្នាក់ប្រហាក់ប្រហែល ទៅតាមរចនាសម្ព័ន្ធថ្មីមកក្រសួងមុខងារសាធារណៈ ដើម្បីពិនិត្យផ្តល់យោបល់ និងរៀបចំបែបបទ នីតិវិធី ដើម្បីឆ្លើយតបឬស្នើសុំតែងតាំង ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

៣.២-បន្ទាប់ពីទទួលបានលិខិតបទដ្ឋានគតិយុត្តឯកត្តភូតពាក់ព័ន្ធនឹងការតែងតាំងមន្ត្រីរាជការស៊ីវិល ក្រសួងមុខងារសាធារណៈ ត្រូវរៀបចំធ្វើបច្ចុប្បន្នភាពក្នុងប្រព័ន្ធព័ត៌មានវិទ្យារបស់ក្រសួងមុខងារសាធារណៈ ឱ្យស្របតាមមុខតំណែង ដោយពុំចាំបាច់មានសំណើផ្សេងទៀតឡើយ។

៣.៣- សំណើសុំតែងតាំងឡើងវិញមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងគ្រប់គ្រងនិងថ្នាក់ប្រហាក់ប្រហែល ត្រូវភ្ជាប់មកជាមួយនូវសំណុំឯកសារពាក់ព័ន្ធ ដូចមានកំណត់ក្នុងឧបសម្ព័ន្ធនៃសេចក្តីណែនាំនេះ។

## ៤- ការរៀបចំសមាហរណកម្មមន្ត្រីទៅក្នុងរចនាសម្ព័ន្ធថ្មីរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួង រដ្ឋលេខាធិការដ្ឋាន និងស្ថាប័នចំណុះអង្គការនីតិប្រតិបត្តិ

មន្ត្រីរាជការស៊ីវិល រួមមាន ប្រធានការិយាល័យ អនុប្រធានការិយាល័យ ឬថ្នាក់ប្រហាក់ប្រហែល និងមន្ត្រីដែលមិនទាន់មានមុខតំណែង ព្រមទាំងមន្ត្រីជាប់កិច្ចសន្យា ត្រូវធ្វើសមាហរណកម្មទៅក្នុងរចនាសម្ព័ន្ធថ្មីថ្នាក់នាយកដ្ឋាន ឬអង្គភាពប្រហាក់ប្រហែល ដោយប្រកាសរបស់រដ្ឋមន្ត្រី ឬសេចក្តីសម្រេចសមស្របផ្អែកលើលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ៥- ការរៀបចំរចនាសម្ព័ន្ធនៅក្រោមអង្គភាពកម្រិតនាយកដ្ឋានឬថ្នាក់ប្រហាក់ប្រហែល

៥.១- ការរៀបចំរចនាសម្ព័ន្ធនៅក្រោមអង្គភាពកម្រិតនាយកដ្ឋានឬថ្នាក់ប្រហាក់ប្រហែល ត្រូវគិតគូរដោយផ្អែកលើការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន និងប្រតិបត្តិឱ្យបានខ្ជាប់ខ្ជួននូវអភិក្រម "រៀបចំផ្ទះឱ្យរៀបរយ" និង "ពង្រឹងជាជាងពង្រីក" របស់រាជរដ្ឋាភិបាល។

៥.២- ការរៀបចំបែងចែកជាការិយាល័យនីមួយៗ ត្រូវផ្អែកលើភារកិច្ចរបស់អង្គភាពកម្រិតនាយកដ្ឋាន ឬថ្នាក់ប្រហាក់ប្រហែល និងត្រូវពិចារណាអំពីចំនួនមន្ត្រីក្នុងការអនុវត្តភារកិច្ច សម្រាប់ជាមូលដ្ឋានក្នុងការបង្រួម កែសម្រួល លុប ឬរក្សាចំនួនការិយាល័យ។

៥.៣- ក្នុងករណីដែលក្រសួង ស្ថាប័ន ពិនិត្យឃើញថាអង្គភាពកម្រិតនាយកដ្ឋានឬថ្នាក់ប្រហាក់ប្រហែលរបស់ខ្លួន មិនមានភាពចាំបាច់ក្នុងការបង្កើតរចនាសម្ព័ន្ធជាការិយាល័យ ក្រសួង ស្ថាប័ន អាចរៀបចំជាមន្ត្រីជំនាញ ដើម្បីទទួលបន្ទុកអនុវត្តភារកិច្ចក្នុងអង្គភាពកម្រិតនាយកដ្ឋានឬថ្នាក់ប្រហាក់ប្រហែលនោះតែម្តង ដោយមានតែប្រធានអង្គភាពកម្រិតនាយកដ្ឋានឬថ្នាក់ប្រហាក់ប្រហែល អនុប្រធាននាយកដ្ឋាន និងមន្ត្រីជំនាញ។

៥.៤- ការរៀបចំតែងតាំងឡើងវិញមន្ត្រីរាជការស៊ីវិលទៅក្នុងមុខតំណែងគ្រប់គ្រងថ្នាក់ការិយាល័យ អនុប្រធានការិយាល័យ ឬថ្នាក់ប្រហាក់ប្រហែល ត្រូវអនុវត្តតាមចំណុច១.៤ នៃសេចក្តីណែនាំនេះ។

## ៦- យន្តការតាមដាននិងជំរុញការអនុវត្ត

ប្រគល់ភារកិច្ចជូនលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល នីតិកាលទី៧នៃរដ្ឋសភា គ.វ.រ. ដើម្បីត្រួតពិនិត្យតាមដាននិងជំរុញការអនុវត្តសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

ទទួលបានសេចក្ដីណែនាំនេះ រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ គណៈកម្មាធិការលើកកម្ពស់អភិបាលកិច្ចក្រសួង ស្ថាប័ន ចំណុះអង្គការនីតិប្រតិបត្តិ ត្រូវអនុវត្តសេចក្ដីណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ៤កើត ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដមឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ